# កិច្ចការបញ្ចប់មេរៀនទី១២-គុណម្ដាយឪពុក

**អំណាន:** ចូរច្រៀងចម្រៀងខាងក្រោម រួចឆ្លើយនឹងសំណួរ ។

ចម្រៀង: លំនាំបទខ្ញុំមានមាត់សម្រាប់និយាយ

១. ខ្ញុំមានពុកម៉ែអ្នកមានគុណ ធ្លាប់រែកពុនចិញ្ចឹមគ្រួសារ
ម៉ែដេរប៉ះចម្អិនអាហារ ពុកធ្វើការភ្ជួរចម្ការស្រែ
បន្ទរៈ មែនហើយភ្ជួរចម្ការស្រែ ។

២. ពុកម៉ែខ្ញុំខិតខំធ្វើការ ទាំងទ្វេហារពុំដែលត្អូញត្អែរ
ការងាររាជការចម្ការស្រែ ធ្វើហូរហែពុំខ្លាចនឿយហត់
បន្ទរៈ មែនហើយពុំខ្លាចនឿយហត់ ។

៣. ខ្ញុំស្រឡាញ់គោរពលោកណាស់ ព្រោះលោកចាស់ពូកែទ្រាំអត់
គុណធំធេងគ្មានដែនកំណត់ ទោះសមុទ្រក៏ប្រៀបពុំបាន
បន្ទរៈ មែនហើយក៏ប្រៀបពុំបាន ។

គូសសញ្ញា ✓ ក្នុងប្រអប់ ☐ ចម្លើយមួយដែលត្រឹមត្រូវ ។

១. តើចម្រៀងខាងលើនិយាយពីអ្វី ?

☐ ក. គុណម្ដាយឪពុក ☐ ខ. ច្រៀម តន្ត្រី

☐ គ. របរកសិកម្ម ☐ ឃ. ដំណើរកម្សាន្ត

២. តើឪពុកម្ដាយមានគុណចំពោះកូនដូចម្ដេច ?

☐ ក. ផ្ដល់កំណើត ចិញ្ចឹមបីបាច់ ថែរក្សា ផ្គង់ផ្គង់ ☐ ខ. ចម្រៀង តន្ត្រី

☐ គ. របរកសិកម្ម ☐ ឃ. ដំណើរកម្សាន្ត

៣. ចូរគូសភ្ជាប់ពីសំណេរពាក្យ ទៅសំណួរពាក្យ ឱ្យបានត្រឹមត្រូវ ?

| សំណេរពាក្យ | សំណួរពាក្យ |
|---|---|
| ចិញ្ចឹម | [ ចំ-កា ] |
| សមុទ្រ | [ រាជៈ-កា ] |
| រាជការ | [ សៈ-ម៉ុត ] |
| ចម្ការ | [ ចិញ-ចឹម ] |

៤. ចូររកបដិសព្ទនឹងពាក្យ " នឿយហត់ "

☐ ក. ពិបាក ☐ ខ. ស្រណុក

☐ គ. ធុញទ្រាន់ ☐ ឃ. សប្បាយ

LIVEWORKSHEETS

៤. ចូរគូសសញ្ញាព្រួញភ្ជាប់ឃ្លាខាងក្រោម ឱ្យបានជាវគ្គចម្រៀងត្រឹមត្រូវ ?

| | |
|---|---|
| ពុកម៉ែខ្ញុំខិតខំធ្វើការ | ធ្វើហូរហែពុំខ្លាចនឿយហត់ ។ |
| ខ្ញុំមានពុកម៉ែអ្នកមានគុណ | ពុកធ្វើការភ្ជួរចម្ការស្រែ ។ |
| ការងាររាជការចម្ការស្រែ | ទាំងទ្វេហារពុំដែលត្អូញត្អែរ |
| ម៉ែដេរប៉ះចម្អិនអាហារ | ធ្លាប់រែកពុនចិញ្ចឹមគ្រួសារ |

## សំណេរ

១. ចូរពន្យល់ពាក្យខាងក្រោម ។

- គុណ ..........................................................................................................................។
- នឿយ ..........................................................................................................................។
- ចិញ្ចឹម ..........................................................................................................................។

៣. ចូរជ្រើសរើសពាក្យ ឬកន្សោមពាក្យក្នុងប្រអប់ទៅបំពេញល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ។

| នឿយហត់ រាជការ ខិតខំ ចម្អិន ចិញ្ចឹម គុណ ភ្ជួរ ត្អូញត្អែរ |
|---|

| | |
|---|---|
| ខ្ញុំមានពុកម៉ែអ្នកមាន............ | ធ្លាប់រែកពុន............គ្រួសារ |
| ម៉ែដេរប៉ះ..............អាហារ | ពុកធ្វើការ............ចម្ការស្រែ |

បន្ទរះ មែនហើយភ្ជួរចម្ការស្រែ ។

| | |
|---|---|
| ពុកម៉ែខ្ញុំ................ធ្វើការ | ទាំងទ្វេហារពុំដែល.............. |
| ការងារ............ចម្ការស្រែ | ធ្វើហូរហែពុំខ្លាច................ |

បន្ទរះ មែនហើយពុំខ្លាចនឿយហត់ ។

LIVEWORKSHEETS